- បានឃើញព្រះរាជក្រឹត្យលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីដូចតទៅ :

# ច្បាប់

## ស្តីពី

## ការបង្ក្រាបល្បែងស៊ីសង

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១:** ត្រូវហាមឃាត់ជាដាច់ខាតការលេងល្បែងស៊ីសងគ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

**មាត្រា ២:** រាល់លិខិតដែលបានអនុញ្ញាតអោយបើកល្បែងស៊ីសងក្រៅពីការអនុញ្ញាតរបស់ រាជរដ្ឋាភិបាល ត្រូវទុកជាមោឃៈ ។

### ជំពូកទី ២

### ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៣:** ការបង្ក្រាបនិងការទប់ស្កាត់ ការលេងល្បែងស៊ីសងគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣

## ទោសប្បញ្ញត្តិ

**មាត្រា ៤:** ជនណាលេងល្បែងស៊ីសងជននោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយម៉ឺនរៀល (១០.០០០៛០០) ដល់ប្រាំម៉ឺនរៀល (៥០.០០០៛០០) ឬដាក់គុកពីមួយសប្តាហ៍ដល់មួយខែ ។

ក្នុងករណីពុំរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំម៉ឺនរៀល (៥០.០០០៛) ដល់ប្រាំសែនរៀល (៥០០.០០០៛) និងដាក់គុកពីមួយខែដល់មួយឆ្នាំ ។

**មាត្រា ៥:** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល (៥.០០០.០០០៛០០) ដល់ម្ភៃលានរៀល (២០.០០០.០០០៛០០)និង ដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ចំពោះអ្នកបើកកន្លែងលេងល្បែងស៊ីសង អ្នកកាន់កាប់ល្បែងស៊ីសង អ្នកចាត់ចែងនិងភ្នាក់ងារស៊ីសង ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់និងដាក់គុកខាងលើនេះជាអតិបរមា ។

**មាត្រា ៦:** កាលណានៅក្នុងវង់ល្បែងមានអនីតិជនម្នាក់ឬច្រើននាក់នៅជាមួយផង ទោសដែលបានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃច្បាប់នេះ ត្រូវយកមកអនុវត្តដល់អតិបរមា ។

**មាត្រា ៧:** ក្នុងករណីណាក៏ដោយ ប្រាក់ដែលដាក់ក្នុងវង់ល្បែង ប្រាក់ដែលមាននៅនឹងខ្លួនអ្នកចាត់ចែងល្បែងនៅនឹងខ្លួនមេល្បែង នៅនឹងខ្លួនភ្នាក់ងារល្បែង នៅនឹងខ្លួនអ្នកជួយស៊ីសងក្នុងវង់ល្បែង នៅនឹងខ្លួនអ្នកទទួលភារកិច្ចខាងគណនេយ្យ នៅនឹងខ្លួនអន្តរការីនិងនៅនឹងខ្លួនអ្នកលេងល្បែង ត្រូវភ្នាក់ងារមានសមត្ថកិច្ចចាប់រឹបអូសហើយធ្វើកំណត់ហេតុអោយបានត្រឹមត្រូវបញ្ជូនទៅតុលាការ ។

វត្ថុតាងសំរាប់បម្រើអោយការលេងល្បែងនោះ ក៏ត្រូវរឹបអូសដូចខាងលើនេះដែរ ។

**មាត្រា ៨:** ការផលិត ការនាំចូលដើម្បីធ្វើអាជីវកម្ម ការលក់ ឧបករណ៍ល្បែងស៊ីសងគ្រប់ប្រភេទដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំសែនរៀល (៥០០.០០០៛០០) ដល់ប្រាំលានរៀល(៥.០០០.០០០៛០០) និងដាក់គុកពីមួយខែដល់មួយឆ្នាំ ។

ឧបករណ៍ជាវត្ថុតាងខាងលើនេះត្រូវរឹបអូស ។ ក្នុងករណីពុំរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់និងដាក់គុកខាងលើនេះជាអតិបរមា ។

**មាត្រា ៩:** ប្រាក់និងវត្ថុតាងដែលរឹបអូសបានដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវ បញ្ជូនទៅតុលាការដើម្បីសំរេចរឹបអូសជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

ចំពោះប្រាក់រង្វាន់សំរាប់ភ្នាក់ងារមានសមត្ថកិច្ច អង្គភាពនិងជនដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១០:** ក្រៅពីរាជរដ្ឋាភិបាល អាជ្ញាធរណាក៏ដោយក៏គ្មានសិទ្ធិចេញលិខិតអនុញ្ញាតអោយបើកល្បែងស៊ីសងនៅទីណាក៏ដោយជាដាច់ខាត ។ មន្ត្រីឬភ្នាក់ងាររាជការណាដែលនៅតែចេញលិខិតអនុញ្ញាតលេងបើកអោយល្បែងស៊ីសង ត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ។

**មាត្រា ១១:** ជនណាដែលចេញមុខការពាររង់ល្បែងស៊ីសងឬបនល្បែងស៊ីសងគ្រប់ប្រភេទនៅទីណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំដល់ប្រាំឆ្នាំ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១២:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣:** ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២**
**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
**ស ខេង យូ ហុកគ្រី**

* * *